## ផ្ដើមពីបុគ្គល...

មុនជជែកវែកញែកដល់រឿងជាតិ
មុននឹងសុំសង្គមឱ្យប្រែផ្លាស់
ម្ដាយឪពុកប្រមុខនៃគ្រួសារ
ឱ្យកិរិយានិងការនិយាយស្ដី
តើលោកអ្នកដាក់កាយជាគំរូ
ប្រទ្បីសបើសរើសអើងផ្ទើងទ្រនង់
នៅក្នុងផ្ទះមានទេឧបេក្ខា
ឬមោហាយកហិង្សាជាមុខ
ធ្វើដំណើរតើអ្នកចេះគិតក្រែង
មុនស្រែកដេរចង់កែគេឯទៀត
សង្គមល្អកកើតពីបុគ្គល
ស្រុកបានថ្កើងឡើងយសខ្ពស់ចេស្ដា
ឃើញក្រហើយម្ដេចឡើយប្រឹងអុកឡុក
ខ្លាចបាត់បង់មិនប្រុងថៃឃ្នាតខ្មី
ទឹកតក់ៗស្រក់ជោរហូរជាស្ទឹង
ខ្លាចតែអត់អំណាត់និងបដិញ្ញា

## ...ឈានដល់ជាតិ

ខ្ញុំសុំឆ្លៀតសាកសួរសំណួរខ្លះ
អ្នកធ្លាប់ដាស់សតិខ្លួនដែរអី?
បានធ្វើការអប់រំកូនប្រុសស្រី
គេប្រពៃសមសក្តិអ្នកមានពង្ស?
ឬទូម្ទូបណ្ដោយឱ្យកូនល្ងង់
ឱ្យគេលង់ធ្លាក់ក្នុងអបាយមុខ?
មានមេត្តារក្សាគ្នាដោយសុខ
បង្កទុក្ខដល់គ្រួសារមិត្តញាតិ?
ឬប្រជែងមួយឈ្នះស្នះគេព្រាត
ឬកមារយាទអ្នកគួរកែសិនរ៉ា?
បើរវល់ប្រចាំតើឆ្នាំណា
ខ្វះត្រង់ណាជួយគ្នាទៅវាថ្វី?
មិននៅស្រុកស្រែកខ្លាចបាត់ទឹកដី
ខ្លាចក្រក្រីមិនលៃខំធ្វើការ?
ម្នាក់ៗប្រឹងគង់នឹងដូចប្រាថ្នា
ចេះត្រឹមថាអ្នកណាក៏ធ្វើបាន៕

ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី